# ស្ថាននាមប្រាសាទ «ត្រពាំងរពៅ» និងសិលាចារឹកប្រាសាទនេះ (K.៦៩១)

## ១- ព័ត៌មានទូទៅ

***ប្រាសាទត្រពាំងរពៅ*** ឬ ***ប្រាសាទត្រពាំងល្ពៅ*** ឬក៏ ***ប្រាសាទគុកត្រពាំងល្ពៅ*** ហើយពេលខ្លះក៏ហៅថា ***ប្រាសាទនាងពៅ*** ជាប្រាសាទមួយនៅខាងត្បូងបារាយណ៍ខាងលិច ស្ថិតនៅក្នុងភូមិប្រីចាស់ ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប។ ប្រាសាទនេះមានប្រាង្គបីសង់ពីឥដ្ឋ រត់ជួរជើងត្បូង បែរមុខទៅកើត។ មុខខាងកើតនៃប្រាង្គនីមួយៗមានស៊ុមទ្វារធ្វើពីថ្មភក់និងមានសសរពេជ្ររាង៨ជ្រុង ឯមុខផ្សេងទៀតជាទ្វារបញ្ឆោត[១]។ ប្រាង្គកណ្ដាលបាក់បែកអស់នៅសល់តែស៊ុមទ្វារ សសរពេជ្រ និងផ្ដែរ បើប្រាង្គខាងជើងនិងខាងត្បូងនៅសល់សំណង់ផ្នែកខាងក្រោមខ្លះ។ កាលពីខែមីនា ឆ្នាំ២០២៣កន្លងទៅ មន្ត្រីជំនាញនៃអាជ្ញាធរជាតិអប្សរា បានបញ្ចប់ការជួសជុលប្រាង្គខាងត្បូង ហើយកំពុងជួលជុលប្រាង្គខាងជើងជាបន្ត[២]។ នៅទិសអាគ្នេយ៍ មានស្នាមឥដ្ឋរៀបជាបន្ទប់ដែលគេសព្វថ្ងៃហៅថាហោត្រៃ។ ជុំវិញប្រាសាទមានកំពែងឥដ្ឋដែលមានខ្លោងទ្វារនៅខាងកើត កសិន្ធុ និងគោកនៅផ្នែកខាងត្បូងនិងខាងលិច។ ពីប្រាសាទត្រពាំងរពៅ ទៅទិសឦសាន ប្រហែល ២០០ ម៉ែត្រ មានត្រពាំងធំមួយដែលជាសំណង់ឧបសម្ព័ន្ធរបស់ប្រាសាទ ក្លាយជាវាលស្រែ[៣]និងកាត់ដោយផ្លូវធ្វើដំណើរ។ នៅមេទ្វារទាំងសងខាងនៃប្រាង្គខាងត្បូងមានសិលាចារឹកពីរផ្ទាំងដែលចុះលេខសារពើភណ្ឌ K.៦៩០ ឯមេទ្វារខាងត្បូងនៃហោត្រៃមានសិលាចារឹកមួយចុះលេខសារពើភណ្ឌ K.៦៩១។

***ត្រពាំងរពៅ*** ជាឈ្មោះហៅប្រាសាទនេះតាំងបុរាណមក ព្រោះសិលាចារឹក K.៦៩០ មេទ្វារខាងជើងប្រើពាក្យថា «***វ្រះកម្រតេងអញអាយត្រវាងរពៅ***» (ប.២៧-៨) និង «***វ្រះអាយ***

[១] https://cisark.mcfa.gov.kh/core/showsite.php?id=445។

[២] អាជ្ញាធរជាតិអប្សរា, ២០២៣។

[៣] អ៊ូ គន្ធា, ២០១៨; ឡាហ្សុងគីយែរ, ១៩១១។ លោក ឡាហ្សុងគីយែរ និយាយថាត្រពាំងនោះនៅចម្ងាយ៩០ ម៉ែត្រពីខាងកើតប្រាសាទទៅវិញ។

**ត្រវាងរពៅ**» (ប.២៩-៣០) ហៅសម្គាល់ប្រាសាទនេះ។ ពាក្យ «**រពៅ**» នេះ ក្រោយមកក្លាយជា «**រពៅ**» រួចក្លាយជា «**ល្ពៅ**»។ ហេតុនេះទើបប្រាសាទនេះឈ្មោះថា **ប្រាសាទត្រពាំងរពៅ** ផង និង **ត្រពាំងល្ពៅ** ផង។ ទោះបីជាយ៉ាងនេះក្ដី «**ល្ពៅ**» ជារុក្ខជាតិវល្លិ៍ដែលយើងស្គាល់សព្វថ្ងៃពុំមែនជាដំណាំក្នុងស្រុកឡើយ តែជាដំណាំមានដើមកំណើតនៅទ្វីបអាមេរិក។ ទាល់តែចាប់ពីឆ្នាំ១៤៩២ ដែលលោក គ្រីស្តុប គូឡុំ រកឃើញទ្វីបអាមេរិក ទើបមានការនាំចេញផលដំណាំពីទឹកដីអាមេរិកទៅកាន់ទ្វីបដទៃ ដែលក្នុងនោះមានល្ពៅផង។ ដូចនេះ វត្តមាន «ល្ពៅ» នៅកម្ពុជាអាចមានរយៈពេលយូរបំផុត ត្រឹមចុងសតវត្សទី១៥ប៉ុណ្ណោះ[២]។ ចំពោះ «**រពៅ**» អ្នកស្រាវជ្រាវបានពន្យល់ថាជាដើមឈើតូចឬចុល្លព្រឹក្សដែលស្ថិតក្នុងប្រភេទ Connarus (Connaraceæ) (Pou & Martin, 1981) ទំនងជាត្រូវនឹងរុក្ខជាតិដែលអ្នកខ្លះហៅថាដើម**ពពោះ លំពស់** ឬ**អំពស់**។ ចំពោះការយកឈ្មោះរុក្ខជាតិក្នុងស្រុកទៅដាក់ឱ្យរុក្ខជាតិចំណូលស្រុកនោះ ពុំមែនមានតែមួយករណីនេះទេ ហើយការប្ដូរឈ្មោះនោះអាចហៅតាមរូបរាង ឬកត្តាផ្សេងទៀត ដែលមិនជាប់ទាក់ទងនឹងពូជឬប្រភេទនៃរុក្ខជាតិនោះឡើយ។ ជាក់ស្ដែងពាក្យថា «**កំទូត/កំទ្វាត**» (កន្ទួត) ក្នុងសិលាចារឹកសំដៅដល់រុក្ខជាតិដែលយើងសព្វថ្ងៃហៅជា «**កន្ទួតព្រៃ**» លុះក្រោយមកក៏ហៅរុក្ខជាតិចំណូលថ្មីនិងនៅក្នុងអម្បូរផ្សេងពីគ្នានោះថា «**កន្ទួត**» ដែរ គឺ **កន្ទួតស្រុក** ដោយសារមានរូបរាងស្រដៀងគ្នា(?)។ ម្យ៉ាងការហៅជា «**កន្ទួតស្រុក**» គឺដោយសារដំណាំនេះ អ្នកស្រុកនិយមដាំក្នុងដីភូមិក្បែរផ្ទះសំបែង ហើយស្គាល់ជាទូទៅនោះ ហៅត្រឹម «**កន្ទួត**»។ យ៉ាងខ្ញីដូច្នេះឯង។ ឯ «**កន្ទួត**» ជារុក្ខជាតិដែលខ្មែរស្គាល់ពីដើមមកច្រើនតែដុះក្នុងព្រៃនោះ ក៏ហៅជា «**កន្ទួតព្រៃ**» ទៅវិញ។ ការបកស្រាយនិងឧទាហរណ៍ខាងលើនេះ ពុំទាន់ពេញលេញទេ ព្រោះ **ល្ពៅ** និង **អំពស់** មានរូបរាងនិងប្រភេទខុសគ្នាស្រឡះ។ យើងមានឧទាហរណ៍ក្នុងរឿងនេះម្យ៉ាងទៀត គឺ **ជនជាតិចិនកន្តាំង** នៅស្រុកខ្មែរមិនមានជាប់ទាក់ទងអ្វីនឹង **កន្តាំង** បន្តិច តែដោយសារ

---

[២] Garcia & Sousa, ២០១៨៖ មានការតំណាលថាល្ពៅ «Kabocha» របស់ជប៉ុនក្លាយមកពីពាក្យ កម្ពុជា ដោយសារនៅសតវត្សទី១៦ ជនជាតិព័រទុយហ្គាល់បានយកល្ពៅពីកម្ពុជាទៅជប៉ុន។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង និង ប៉ោ សុខរីន

ពាក្យដើម **គ័នទុង** ខ្មែរពិបាកថាផង ហើយស្រដៀងនឹងពាក្យខ្មែរថា **កន្ទាំង** ផង ទើបខ្មែរហៅថា **ចិនកន្ទាំងៗ** តែម្តង។ គិតមកដល់ករណីនេះហើយ ទើបយើងប្រឹងរកពាក្យហៅល្ពៅក្នុងភាសាផ្សេងៗទៅ ក៏ឃើញថាពាក្យ «**ល្ពៅ**» ក្លាយមកពីពាក្យក្នុងអំបូរភាសាអូស្ត្រូនេស៊ី «Labu» (លបុ/លពុ)។ ពាក្យនេះ ហៅសំដៅដល់ពពួករុក្ខជាតិវល្លិ៍ពពួកត្រសក់ឃ្លោក ដែលមានរូបរាងតូចធំ ទ្រវែងឬមូល និងមានសម្បុរក្រឡេក្រឡាឬខ្ចាឃ្លោក។ តាមការវិវត្តសូរក្នុងភាសាខ្មែរ យើងអាចយល់បានថាពាក្យដែលខ្ចីមានវិវត្តដូច្នេះ៖ **លបុ/លពុ** > **លបូ/លពូ** > **លបូវ/លពូវ** (**ល្ពូវ/ល្ពៅ**)។ យើងមានការវិវត្ត **អុ** > **អូ** > **អូវ** ដូចជាពាក្យ **ស្រុ** > **ស្រូ** > **ស្រូវ**, **សត្រុ** > **សត្រូ** > **សត្រូវ** ជាដើម។ តាមការបកស្រាយមកនេះ យើងឃើញថាករណីពាក្យ «Lapu» និង «**រពៅ**» ជាពាក្យពីរមានប្រភពពីផ្សេងគ្នា ប៉ុន្តែបានក្លាយទៅជាពាក្យ «**ល្ពៅ**» ដូចគ្នា។ រុក្ខជាតិ «**រពៅ/រពៅ**» នេះ ទំនងជាប្រភេទរុក្ខជាតិដែលមានដុះនៅតាមទីតាំងមានទឹកផង ដ្បិតយើងឃើញមានស្ថាននាមដូចជា **ត្រពាំងរពៅ** និង **ទន្លេរពៅ** ជាដើម។

លោកសាស្ត្រាចារ្យ ហ្សឺក សឺដេស បានសិក្សាសិលាចារឹក K.៦៩១ ជាភាសាបារាំងនៅក្នុងសៀវភៅ សិលាចារឹកនៃប្រទេសកម្ពុជា ក្បាលទី៤ ដែលបោះពុម្ពឆ្នាំ១៩៥២។ ក្រោយមកលោកសាស្ត្រាចារ្យ ហ្វីលីព ចេណ្ណឺរ បានសិក្សាសិលាចារឹកនេះជាភាសាអង់គ្លេសនៅក្នុងស្នាដៃរបស់លោក *Part xml*, № 8 និងបានចុះផ្សាយក្នុងគេហទំព័រ http://sealang.net/ok/corpus.htm។ សិលាចារឹក K.៦៩១ ជាសិលាចារឹកភាសាខ្មែរមាន៨បន្ទាត់ ចុះកាលបរិច្ឆេទនៅមហាសករាជឆ្នាំ៩២៤ (ត្រូវនឹងគ.ស. ១០០២) គឺអាចនៅរវាងចន្លោះរាជ្យព្រះបាទស្រីឧទយាទិត្យវម្ម័ទេវទី១ (គ.ស.១០០១-១០០២) និងព្រះបាទស្រីជ័យវីរវម្ម័ទេវ (គ.ស.១០០២-១០១០)។ អត្ថបទចារឹកនិយាយអំពីបុរសឈ្មោះលោញទានស្ថាបនាទីតម្កល់ព្រះភ្លើង ហើយថ្វាយអ្នកបម្រើ៤នាក់ក្នុងមួយបក្ស (ឬកន្ទះខែ) ដើម្បីឱ្យអ្នកទាំងនោះបង្កបង្កើនផលស្រែសម្រាប់បូជាថ្វាយព្រះភ្លើង និងថ្វាយអង្ករសម្រាប់យជ្ញព្រះភ្លើង និងមានការរៀបចំផ្សេងៗសម្រាប់អាស្រម។ សេចក្តីនៃសិលាចារឹក K.៦៩១ បានបង្ហាញថា **ហោត្រៃ** ប្រាសាទ

នេះ គឺជាទីតម្កល់ព្រះភ្លើង ដោយបញ្ជាក់ថា **លោញទាន** បានស្ថាបនាទីតម្កល់ព្រះភ្លើង (ប.១-២) ហើយថែមទាំងបញ្ជាក់ថាទីនោះជា **អាស្រមព្រះភ្លើង** (ប.៦) ផង។ កន្លងមកមានការសិក្សាខ្លះហើយ អំពីរឿងហោត្រៃ ឬបណ្ណាល័យ នៅតាមប្រាសាទ និងសិលាចារឹកនៅហោត្រៃដែលនិយាយពីការស្ថាបនាព្រះភ្លើង។ លោក Thomas Maxwell (2009) បានសិក្សាយ៉ាងក្បោះក្បាយពីសិលាចារឹក K.១៣១៣ នៅមេទ្វារនៃអគារលេខ៤៥ នៃក្រុមសំណង់ខាងកើត ក្នុងថ្នាទី២នៃប្រាសាទបន្ទាយឆ្មារ ដែលនិយាយពីការតម្កល់ «**វ្រះវ្លេងស្វគ៌**» (ព្រះភ្លើងសួគ៌)។ តាមជំនឿ **លោកបាល** (ទេវតារក្សាលោក) ឬ **ទិក្បាល** (ទេវតារក្សាទិស) គេជឿថាមានទេវតា៨អង្គរក្សាទិសទាំង៨ ឯ **ព្រះអគ្និ** ឬ **ព្រះអគ្គី** គឺជាទេវតាគ្រប់គ្រងរក្សាលោកនៅទិសអាគ្នេយ៍។ តាមជំនឿនេះហើយ បុព្វបុរសខ្មែរ តម្កល់ព្រះភ្លើងនៅហោត្រៃប្រាសាទត្រពាំងរពៅ និងប្រាសាទផ្សេងទៀត ស្ថិតនៅទិសអាគ្នេយ៍នៃប្រាង្គសំខាន់ ពុំនោះទេអគារណាក៏ដោយ ដែលស្ថិតនៅទិសអាគ្នេយ៍ក៏អាចធ្វើជាកន្លែងបូជាព្រះភ្លើងដែរ។

## ២- អត្ថបទដើមជាអក្សរខ្មែរទំនើប

១- ៩២៤គកបិកេតិ(អាគុ)ជ្យ[៥] ចន្ទ្រវាររនុលោញទានិ

២- ស្ថាបនាវ្រះវ្លេងបិជូនខ្ញុំឃោកញ្ជេសិ[៦] ឃោចាម្ប[៧]

៣- តៃមាយតៃកនិរុនិតោយិខ្នេតឃោកនិស្រាចិ

៤- ឃោកញ្ជានិតៃបន្ទាសិតៃកឥនិ[៨] តោយិណ្ដោច

៥- ថ្ងៃស្រេវ្រះវ្លេងឱយរង្គោទ្នាលិម្វាយយជ្ញវ្រះ

៦- វ្លេងប្រតិទិនគិបទះស្ថានជាអាគ្រមវ្រះវ្លេង

---

[៥] លោក សឺដេស អានតៃ ---ៗ ដោយលោកលើកឡើងថា ប្រឡោះថ្មធំពេកបើយកពាក្យ «បុស្យ» មកបំពេញ, តែតូចពេកបើយកពាក្យ «អាគ្វយុជ្យ»។ ឯលោក ចេណ្ណឹរ ស្នើឱ្យបំពេញថា អាគ្វយុជ្យ។

[៦] លោក សឺដេស និងលោក ចេណ្ណឹរ អានជា កញ-១។

[៧] លោក សឺដេស និងលោក ចេណ្ណឹរ អានជា តៃ---។

[៨] លោក សឺដេស និងលោក ចេណ្ណឹរ អានតៃ ក-ន។

អត្ថបទដោយៈ ហ៊ុន ឈុនតេង និង ប៉ៅ សុខវីន

៧- កល្បណាតស្មិងចន្ទ្របូរ[9]សាមិ[10]បុរោហិតវ្រះ

៨- នេះគិតបរិបាលអាគ្រម//๏

## ៣- អត្ថបទប្រែសម្រួល

(១-៤) នាមហាសករាជឆ្នាំ៩២៤ ទី៣កើត ខែអស្សុជ ថ្ងៃចន្ទ លោញទានស្ថាបនា (ទីតម្កល់)ព្រះភ្លើង គប្បីថ្វាយអ្នកបម្រើ(មាន) ឃោកញ្ចោស ឃោចាម្ប តៃមាយ (និង)តៃកន រុន បម្រើខែខ្នើត។ ឃោកនស្រាច ឃោកញ្ជាន តៃបន្ទាស (និង)តៃកឥន បម្រើខែរនោច។

(៤-៦) (អ្នកបម្រើទាំងនោះត្រូវ)ធ្វើស្រែ(សម្រាប់បូជាថ្វាយ)ព្រះភ្លើង (ដោយត្រូវ) ថ្វាយអង្ករ១ទ្នាល សម្រាប់បូជាយជ្ញព្រះភ្លើងរៀងរាល់ថ្ងៃ។

(៦-៧) លំនៅស្ថាន(ចំណុះ)ជាអាស្រមព្រះភ្លើង (ត្រូវ)រៀបចំគ្រឿងរណ្ដាប់ដល់ស្មឹង ចន្ទ្របូរជារឿយៗ។

(៧-៨) បុរោហិតព្រះនេះជាអ្នកថែរក្សាអាស្រម។

## ៤- សន្និដ្ឋានរួម

សិលាចារឹកប្រាសាទត្រពាំងរពៅ ឬប្រាសាទគុកត្រពាំងល្ពៅ K.៦៩១ មានតម្លៃខាងទិដ្ឋភាពនៃការសិក្សាអំពីស្ថាននាម រុក្ខនាម ប្រវត្តិពាក្យសព្ទ និងខាងទិដ្ឋភាពជំនឿសាសនា មានការថែរក្សាអំពើបុណ្យនាសម័យបុរាណ គឺពុំមែនត្រឹមតែតម្កល់ព្រះហើយចប់ទេ ប៉ុន្តែត្រូវគិតគូរ ចាត់ចែងឱ្យមានអ្នកបម្រើ ស្មឹង បុរោហិតជាដើមសម្រាប់ធ្វើឱ្យប្រាសាទមានដំណើរការទៅមុខដោយរលូននិងបិតបេរ។ ម្យ៉ាងទៀតសិលាចារឹកនេះបានផ្ដល់ភស្តុតាងពីតួនាទីរបស់ «ហោត្រៃ» នៃប្រាសាទថាជាទីបូជាព្រះភ្លើងផងដែរ។

[9] លោក សឺដេស និងលោក ចេណ្ណឹរ អានជា ចន្ទ្របុរ តែតាមការពិនិត្យសំណៅផ្ទិតគឺ ចន្ទ្របូរ។

[10] លោក សឺដេស និងលោក ចេណ្ណឹរ អានជា លាំមិ។ ផ្អែកតាមទម្រង់ សា នៅក្នុងពាក្យ ស្រាចិ (ប.៣), និង ស្ថាន (ប.៧) យើងអាចទាញថាពាក្យនេះគឺ សាមិ។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង និង ប៉ៅ សុខវីន

## ៥- វាក្យសព្ទ

| | |
|---|---|
| **អគុជ្យ** | (សំ. អគ្វយុជ)= ខែអស្សុជ។ |
| **ចន្ទ្រវារ** | (សំ.) ថ្ងៃចន្ទ។ |
| **វ្រះវ្លេង** | > ព្រះភ្លើង, គឺព្រះអគ្និដែលអ្នកកាន់សាសនាព្រាហ្មណ៍គោរពបូជា។ |
| **រង្កោ** | > អង្ករ។ |
| **ទ្នាល** | ខ្នាតសម្រាប់វាល់អង្ករ។ |
| **ប្រតិទិន** | (សំ.) រៀងរាល់ថ្ងៃ។ |
| **បទះស្ថាន** | (សំ. បទះ > ផ្ទះ) លំនៅស្ថាន។ |
| **កល្បនា** | (សំ.) រៀបចំ, បង្កើត, គ្រឿងរណ្ដាប់បូជា។ |
| **ស្មិង** | > ស្មឹង, អ្នករៀបចំធ្វើពិធីបូជា។ ក្នុងបរិបទសព្វថ្ងៃ ស្មឹងជារូបអ្នកតា ហៅថា ស្មឹងអ្នកតា ជាអ្នកនាំអ្នកស្រុកភូមិឱ្យធ្វើពិធីទាន់ខែទាន់រដូវ។ |
| **សាមិ** | (~សាំ)= ដដែលៗ, ញឹកញយ, រឿយៗ។ |
| **បរិបាល** | (~បរិបាលន, សំ.)= រក្សា, គ្រប់គ្រង, ការពារ។ |

## បញ្ជីឯកសារ

Cœdès, George. (1952). Inscription de l'édifice annexe de Pràsàt Trapăṅ Ropou. *Inscriptions du Cambodge* (Vol. IV, pp. 151). Paris: Editions de Boccard.

Garcia, M. P., & Sousa, L. D. (Eds). (2018). *Global History and New Polycentric Approaches: Europe, Asia and the Americas in a World Network System* (pp. 166). Basingstoke: Springer Nature.

Lajonquière, L. de. (1911). Prasat Trapeang Repou. *Inventaire Descriptif des Monuments du Cambodge* (Tome Troisième, pp.132-3). Paris: Leroux.

អត្ថបទដោយ៖ ហ៊ុន ឈុនតេង និង ប៉ោ សុខរីន

Maxwell, T. S. (2009). A New Khmer and Sanskrit Inscription at Banteay Chmar. *Udaya, Journal of Khmer Studies*, *10*, 135-201.

Pou, S., & Martin, M. A. (1981). Les noms de plantes dans l'épigraphie du vieux-khmère. *Asie du Sud-Est et Monde Insulindien Paris*, *12*(1-2), 3-73.

## គេហទំព័រ

អ៊ូ គង្គា (២០១៨). *ប្រាសាទត្រពាំងល្ពៅ. HERITAGE_KH.* ក្នុង https://heritagekh.wordpress.com/2018/08/13/%E1%9E%94%E1%9F%92%E1%9E%9A%E1%9E%B6%E1%9E%9F%E1%9E%B6%E1%9E%91%E1%9E%8F%E1%9F%92%E1%9E%9A%E1%9E%96%E1%9E%B6%E1%9F%86%E1%9E%84%E1%9E%9A%E1%9E%96%E1%9F%85/

អាជ្ញាធរជាតិអប្សរា https://apsaraauthority.gov.kh/2023/08/09/restoring-the-northern-tower-of-trapeang-lpeou-temple/

CISARK https://cisark.mcfa.gov.kh/core/showsite.php?id=445

SEALANG http://sealang.net/ok/corpus.htm

## បញ្ជីរូបភាព



*សំណៅសិលាចារឹកប្រាសាទត្រពាំងល្ពៅ K.៦៩១ (រូបថត៖ EFEO តាមរយៈ CISARK )*



*អត្ថបទចម្លងសិលាចារឹកប្រាសាទត្រពាំងល្ពៅ K.៦៩១ (រូបថត៖ ហ៊ុន ឈុនតេង )*

*អត្ថបទដោយ៖ ហ៊ុន ឈុនតេង និង ប៉ោ សុខវីន*



ប្រាសាទត្រពាំងល្ពៅ (រូបថត៖ អាជ្ញាធរជាតិអប្សរា)



ប្រាសាទត្រពាំងល្ពៅ (រូបថត៖ អាជ្ញាធរជាតិអប្សរា)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង និង ប៉ៅ សុខវិន



រូបថតរហោព្រះភ្លើងនៅជ្រុងអាគ្នេយ៍ប្រាសាទ (រូបថត៖ EFEO_ CAM10148)



រូបថតហោព្រះភ្លើងនៅជ្រុងអាគ្នេយ៍ប្រាសាទ (រូបថត៖ EFEO_ CAM10149)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង និង បៅ សុខវីន